# របៀបវាយយូនីកូដខ្មែរ

ប្រសិនបើអ្នកធ្លាប់បានប្រើពុម្ពអក្សរខ្មែរចាស់ៗ ( លីមូន, Battambang, ABC, etc.) ពីមុនមក នោះអ្នកគ្រាន់តែចំណាយពេលបន្តិចបន្តួចដើម្បីស៊ាំទៅនឹងពុម្ពអក្សរថ្មីវិញ ( ពុម្ពអក្សរ យូនីកូដ ) ។ តែពីរថ្ងៃ ឬ បីថ្ងៃ អ្នកនឹងអាចវាយបានលឿនជាងមុន ។

យូនីកូដមិនមែនគ្រាន់តែជាពុម្ពអក្សរបន្ថែមមួយទៀតនោះទេ ។ យូនីកូដគឺជាខ្នាតគំរូអន្តរជាតិថ្មីមួយសម្រាប់ភាសាខ្មែរ ។ កុំព្យូទ័រទូទាំងពិភពលោកនឹងយល់ភាសាខ្មែរ ពេលប្រើពុម្ពអក្សរយូនីកូដ។ យូនីកូដក៏ជាខ្នាតគំរូថ្មីមួយដែរ សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ពុម្ពអក្សរចាស់ៗនឹងត្រូវបានគេបំភ្លេច ក្នុងប៉ុន្មានឆ្នាំខាងមុខទៀត ហើយអត្ថបទទាំងអស់នឹងសុទ្ធតែជាយូនីកូដ ។

គ្រប់ពុម្ពអក្សរយូនីកូដទាំងអស់មានការបម្លែងរហស្សលិខដូចគ្នា មានន័យថា ពេលដែលអត្ថបទមួយត្រូវបានវាយជាពុម្ពអក្សរយូនីកូដ នោះវាអាចត្រូវបានផ្លាស់ប្តូរទៅជាពុម្ពអក្សរយូនីកូដផ្សេងទៀតបាន ហើយអត្ថបទនោះនឹងនៅរក្សាទ្រង់ទ្រាយយ៉ាងត្រឹមត្រូវ ។

ភាពខុសគ្នាមួយក្នុងចំណោមភាពខុសគ្នាដ៏សំខាន់បំផុតរវាងរបៀបវាយចាស់ៗ និង យូនីកូដនោះគឺ ពេលប្រើប្រាស់ពុម្ពអក្សរថ្មី មានគ្រាប់ចុចមួយលើក្តារចុចសម្រាប់តាងឲ្យស្រៈនិមួយៗ រួមមាន ៀ, ឿ, ោ, ៅ, ើ, ាំ,ោះ ។ល។ ក្នុងយូនីកូដ អ្នកអាចវាយអក្សរម្តងទាំងអស់ដូចក្នុងភាសាខ្មែរ មានន័យថា មិនចាំបាច់វាយដោយផ្នែកនោះទេ ។ ចំណុចសំខាន់នោះ អ្នកអាចវាយតាមលំដាប់ប្រកប មិនមែនវាយពីឆ្វេងទៅស្តាំដូចដែលអ្នកសរសេរដោយដៃឡើយ ។ ជាឧទាហរណ៍ ប្រសិនបើអ្នកចង់វាយពាក្យ'លើ' ជាមួយពុម្ពអក្សរចាស់ៗអ្នកត្រូវសរសេរ ៖

 េ + ល + ី

ប៉ុន្តែជាមួយនឹងពុម្ពអក្សរថ្មីវិញ អ្នកត្រូវវាយ ៖

ល + ើ

តាមឧទាហរណ៍ខាងលើ អ្នកនឹងឃើញថា មិនត្រឹមតែគ្រាប់ចុចប៉ុណ្ណោះទេដែលខុសគ្នា ប៉ុន្តែអ្នកថែមទាំងត្រូវវាយព្យញ្ជនៈមុន ទើបបន្ទាប់មកវាយស្រៈ ដូចដែលអ្នកប្រកប ( ល ... ើ).

អ្វីដែលប្លែកបំផុត ក្នុងរបៀបវាយថ្មីនេះគឺ ជើងព្យញ្ជនៈ មិនត្រូវបានដាក់បញ្ចូលក្នុងក្តារចុចទៀតឡើយ ។ ដូច្នេះដើម្បីវាយជើងព្យញ្ជនៈ អ្នកត្រូវប្រើគ្រាប់ចុចពីរផ្សេងគ្នា ៖ គ្រាប់ចុចមួយចង្អុលបង្ហាញថាព្យញ្ជនៈបន្ទាប់គឺជាជើងព្យញ្ជនៈ និង បន្ទាប់មកគ្រាប់ចុចធម្មតាសម្រាប់ព្យញ្ជនៈនោះ ។ ឧទាហរណ៍ ដើម្បីសរសេរពាក្យ 'ក្ដី' អ្នកចាំបាច់ត្រូវវាយ ៖

ក + ្ + ដ + ី

នេះជាមធ្យោបាយមួយ ដែលជួយបង្កើនល្បឿនក្នុងការវាយឲ្យបានលឿន ព្រោះថាអ្នកមិនចាំបាច់ត្រូវចាំទីតាំងជើងព្យញ្ជនៈទាំងអស់លើក្ដារចុចទេ ។

នេះគ្រាន់តែជាឧទាហរណ៍ខ្លះៗក្នុងការនាំអ្នកឲ្យស្គាល់ពីរបៀបថ្មីក្នុងការវាយអត្ថបទ ។ ឥឡូវនេះ យើងនឹងចាប់ផ្ដើមយ៉ាងលម្អិតមួយជំហានម្ដងៗ ដោយជាដំបូងចាប់ផ្ដើមពីការស្វែងយល់តួអក្សរខ្មែរ ។

# ព្យញ្ជនៈ ស្រៈ និង សញ្ញា ក្នុងភាសាខ្មែរ

ព្យញ្ជនៈ

| | | | | | | | |
|---|---|---|---|---|---|---|---|
| ក | ខ | គ | ឃ | ង | | | |
| ច | ឆ | ជ | ឈ | ញ | | | |
| ដ | ឋ | ឌ | ឍ | ណ | | | |
| ត | ថ | ទ | ធ | ន | | | |
| ប | ផ | ព | ភ | ម | | | |
| យ | រ | ល | វ | ស | ហ | ឡ | អ |

ស្រៈពេញតួ

ខ្មែរទំនើបមានស្រៈពេញតួ ចំនួន ១៤ តួ ៖

| | | | | | | |
|---|---|---|---|---|---|---|
| ឥ | ឦ | ឧ | ឩ | ឪ | ឭ | ឬ |
| ឫ | ឭ | ឮ | ឯ | ឱ | ឲ | ឳ |

ស្រៈនិស្ស័យ

ក្នុងវចនានុក្រម ជួន ណាត ដែលជាឯកសារយោងបុរាណរបស់ខ្មែរ មានស្រៈនិស្ស័យចំនួន ២០ ៖

| | | | | | | |
|---|---|---|---|---|---|---|
| ា | ិ | ី | ឹ | ឺ | ុ | ូ |
| ួ | ើ | ឿ | ៀ | េ | ែ | ៃ |
| ោ | ៅ | ុំ | ំ | ាំ | ះ | |

ប៉ុន្តែ តាមប្រព័ន្ធខ្មែរទំនើបដែលបានបង្រៀនក្នុងសាលា បានបន្ថែមស្រៈ បី បន្ថែមទៀត ដូច្នេះស្រៈត្រូវឡើងដល់ ២៣ តួ ។ ស្រៈទាំងនេះត្រូវបានបញ្ចូលផងដែរក្នុងក្តារចុចគឺ ៖

| | | |
|---|---|---|
| ុះ | េះ | ោះ |

មានស្រៈផ្សំដទៃទៀតដែលមានលក្ខណៈវិនិច្ឆ័យដូចស្រៈខាងលើ (ផ្សំស្រៈជាមួយនឹងសញ្ញារះមុខ) អាចចាត់ទុកជាស្រៈផងដែរ ប៉ុន្តែដោយសារពួកវាមិនត្រូវបានទទួលស្គាល់ដោយប្រភពណាមួយ ដូច្នេះពួកវាមិនត្រូវបានរួមបញ្ចូលក្នុងក្តារចុចទេ ។ វាត្រូវបានវាយដោយគ្រាប់ចុចពីរផ្សេងគ្នា៖

| | | |
|---|---|---|
| ិះ | ឹះ | ែះ |

តួអក្សរប្តូរព្យញ្ជនៈ (វណ្ណយុត្តិ ៊ និង វណ្ណយុត្តិ ៉)

| | |
|---|---|
| ៊ | ៉ |

ត្រីសព្ទ និង មូសិកទន្ត ។ ពេលដែលតាមពីក្រោយដោយស្រៈលើ ត្រីសព្ទ ឬ មូសិកទន្ត ត្រូវបានប្តូររូបរាងមកជាស្រៈ ុ ដោយស្វ័យប្រវត្តិ ។

សញ្ញាលើ (វណ្ណយុត្តិដែលនៅលើ)

| | | | | | |
|---|---|---|---|---|---|
| ៍ | ័ | ៏ | ៎ | ់ | ៑ |

ទណ្ឌឃាត សំយោគសញ្ញា អស្តា កាកបាទ បន្តក់ និង វិរាម ។

របាទ

| |
|---|
| ៌ |

សញ្ញាដែលដាក់ពីក្រោយព្យញ្ជនៈ

| | |
|---|---|
| ះ | ៈ |

រះមុខ និង យុគលពិន្ទុ

សញ្ញាវណ្ណយុត្តិខ្មែរ

| | | | | | |
|---|---|---|---|---|---|
| ។ | ៕ | ៖ | ៗ | ៙ | ៚ |

ខណ្ឌ បរិយោសាន ចំណុចពីរគូ លេខទោ ភ្នែកមាន់ និង គោមូត្រ

សញ្ញាវណ្ណយុត្តិឡាតាំងដែលប្រើក្នុងភាសាខ្មែរ

សញ្ញាឧទាន សញ្ញាសួរ សញ្ញាវិឡារ សញ្ញាចុច

| | | | |
|---|---|---|---|
| ! | ? | “ | . |

លេខខ្មែរ

| | | | | |
|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ |
| ៦ | ៧ | ៨ | ៩ | ០ |

និមិត្តសញ្ញារូបិយវត្ថុរៀល

| |
|---|
| ៛ |

លេខទស្សទាយខ្មែរ

| | | | | |
|---|---|---|---|---|
| ៱ | ៲ | ៳ | ៴ | ៵ |
| ៶ | ៷ | ៸ | ៹ | ៰ |

កាលបរិច្ឆេទ ច័ន្ទគតិ

| | | | | | | |
|---|---|---|---|---|---|---|
| ᧠ | ᧡ | ᧢ | ᧣ | ᧤ | ᧥ | ᧦ |
| ᧧ | ᧨ | ᧩ | ᧪ | ᧫ | ᧬ | ᧭ |
| ᧮ | ᧯ | ᧰ | ᧱ | ᧲ | ᧳ | ᧴ |
| ᧵ | ᧶ | ᧷ | ᧸ | ᧹ | ᧺ | ᧻ |
| ᧼ | ᧽ | ᧾ | ᧿ | | | |

សញ្ញាផ្សេងទៀតដែលប្រើសម្រាប់ភាសាខ្មែរបុរាណ ឬ សម្រាប់សំស្ក្រឹត ឬ ភាសាបាលី

| | | | | | |
|---|---|---|---|---|---|
| ឝ | ឞ | ៜ | ឨ | ៝ | ៓ |

អក្សរស អក្សរឞ សញ្ញាអាវ៉ាក្រាហា ស្រៈពេញតួ អ៊ុក សញ្ញា អថាខណ្ឌ និង សញ្ញា បាតថាមាសាត់

# ក្តារចុច

កុំព្យូទ័រដែលចង់ប្រើសម្រាប់វាយភាសាខ្មែរ ចាំបាច់ត្រូវដឹងថា អ្វីដែលអ្នកចង់វាយគឺអក្សរខ្មែរ ដូច្នេះពេលដែលអ្នកចុចគ្រាប់ចុច ៖




កុំព្យូទ័រដឹងថាវាត្រូវតែបោះពុម្ពអក្សរ ' ត ' មិនមែនអក្សរ ' T ' ។
អ្នកប្រាប់កុំព្យូទ័រថា អ្នកចង់សរសេរជាអក្សរខ្មែរ " ដោយជ្រើសយកក្តារចុចខ្មែរ " អ្នកអាចដឹងថាតើក្តារចុចរបស់អ្នកស្ថិតក្នុងភាសាអ្វីបាន ដោយមើលទៅជ្រុងខាងក្រោមផ្នែកខាងស្តាំនៃអេក្រង់របស់អ្នក ដូចមានបង្ហាញក្នុងរូបខាងក្រោម ៖




សូមយកចិត្តទុកដាក់ផងដែរលើអក្សរ ' EN ' ។ ' EN ' ជាទម្រង់ខ្លីរបស់ English. ប្រសិនបើអ្នកឃើញអក្សរនេះមានន័យថាអ្នកកំពុងតែប្រើប្រាស់ក្តារចុចជាភាសាអង់គ្លេស ដូច្នេះគ្រាប់ចុចទាំងអស់ដែលអ្នកបានវាយ នឹងលេចឡើងជាភាសាអង់គ្លេស ។

ប៉ុន្តែ ប្រសិនបើឃើញដូច្នេះ ៖




អក្សរ ' CA ' មានន័យថាកុំព្យូទ័ររបស់អ្នកកំពុងប្រើប្រាស់ក្តារចុចខ្មែរ ដូច្នេះគ្រាប់ចុចទាំងអស់ដែលអ្នកបានវាយនឹងលេចឡើងជាតួអក្សរខ្មែរ ។

អ្នកអាចប្តូរដោយងាយរវាងក្តារចុច អង់គ្លេស និង ក្តារចុចខ្មែរដោយ ៖

ចុចគ្រាប់ចុច ប្តូរ ( shift ) និង គ្រាប់ចុច ជំនួស ( Alt ) ក្នុងពេលដំណាលគ្នា ៖ គ្រប់ពេលដែលអ្នកចុចពួកវានោះនឹងមានការផ្លាស់ប្តូរក្តារចុចភ្លាម ។ ប្រសិនបើក្តារចុចបច្ចុប្បន្នជាភាសាអង់គ្លេស (EN) នោះវានឹងប្តូរទៅភាសាខ្មែរ (CA) ហើយប្រសិនបើបច្ចុប្បន្នជាក្តារចុចភាសាខ្មែរ នោះវានឹងប្តូរទៅវាភាសាអង់គ្លេសវិញ ។
ចុចលើអក្សរ EN ដោយប្រើកណ្តុរ ៖ ពេលដែលអ្នកចុចលើអក្សរ EN នោះបង្អួចតូចមួយនឹងលេចឡើងជាមួយនឹងជម្រើសដែលអាចទាំងអស់ ។ ក្នុងបង្អួចនេះ អ្នកគួរចុចលើ CA ( កុំខ្វល់នឹងពាក្យ "Catalan") ។

ដើម្បីសាកល្បងឧទាហរណ៍ទាំងអស់ក្នុងឯកសារនេះ អ្នកត្រូវប្រើក្តារចុចខ្មែរ ។ នៅជ្រុងខាងក្រោមផ្នែកខាងស្តាំនៃអេក្រង់របស់អ្នកគួរតែបង្ហាញអក្សរ CA ។



# របៀបវាយយូនីកូដខ្មែរ

ក្នុងយូនីកូដ តម្រូវឲ្យវាយទៅតាមលំដាប់នៃការប្រកប មិនមែនតាមលំដាប់នៃការសរសេរពីឆ្វេង ទៅស្តាំឡើយ ។ ហើយកុំព្យូទ័រនឹងរៀបអក្សរតាមលំដាប់ដ៏ត្រឹមត្រូវ ។ ដូចដែលយើងបានរៀបរាប់កន្លងមក ពាក្យសាមញ្ញ ដូចជា ៖

លើ

ត្រូវវាយ ៖

ល + ើ

មិនមែន ៖

េ + ល + ី

គ្រប់ពាក្យទាំងអស់ត្រូវគោរពតាមលំដាប់នេះ ។ ព្យាង្គត្រូវវាយទៅតាមក្បួនទូទៅមួយ ៖

ព្យញ្ជនៈ + ជើងព្យញ្ជនៈ + ស្រៈ + សញ្ញា

សម្រាប់អក្ខរាវិរុទ្ធខ្មែរ ព្យញ្ជនៈ និង ស្រៈពេញតួ ត្រូវបានប្រើក្នុងរបៀបដូចគ្នា ដូច្នេះ ព្យញ្ជនៈក្នុងឯកសារនេះ គឺសំដៅទាំងព្យញ្ជនៈ ឬ ស្រៈពេញតួ ។
ស្រៈតែងតែត្រូវបានវាយនៅពីក្រោយព្យញ្ជនៈ ទោះបីជាវាត្រូវបានសរសេរនៅពីមុខ ពីក្រោយ ពីលើ ពីក្រោម ក៏ដោយ ។ កុំព្យូទ័រ នឹងដាក់វាក្នុងទីតាំងដ៏ត្រឹមត្រូវ ។
ស្រៈដែលមានពីរផ្នែក (ដូចជា ោ) ក៏ត្រូវបានវាយនៅពីក្រោយព្យញ្ជនៈ ៖

ល + ិ -> លិ

គ + េ -> គេ

ន + ៅ -> នៅ

ល + ើ -> លើ

ព្យញ្ជនៈ និងស្រៈដែលស្ថិតនៅផ្នែកក្រោមនៃគ្រាប់ចុច ត្រូវបានវាយដោយគ្រាន់តែចុចគ្រាប់ចុចធម្មតា ។ ចំនែកឯ ព្យញ្ជនៈ និង ស្រៈ ដែលស្ថិតនៅផ្នែកលើខាងស្តាំ ត្រូវបានវាយដោយចុចគ្រាប់ចុច ប្តូរ(shift) ជាមួយគ្រាប់ចុចនោះតែម្តង ។




អក្សរខ្លះដែលមិនត្រូវបានប្រើជាញឹកញាប់ ( ស្រៈពេញតួខ្លះ ) ត្រូវបានដាក់នៅផ្នែកលើខាងឆ្វេងនៃគ្រាប់ចុច និង មានពណ៌ប្រផេះនោះ ត្រូវបានចុចដោយគ្រាប់ចុចឆ្លាស់ (Alt Gr) ។




ប្រសិនបើព្យាង្គនោះ មានជើងព្យញ្ជនៈ ណាមួយ ជើងនោះត្រូវបានវាយនៅពីក្រោយព្យញ្ជនៈសំខាន់ ប៉ុន្តែនៅពីមុខស្រៈ (ប្រសិនបើមាន) ។

អ្នកគួរកត់សម្គាល់ដែរថា ព្យញ្ជនៈជើងគឺមិនមាននៅលើក្តារចុច ដូច ពុម្ពអក្សរមុនៗ ( លីមូន ABC ឬ ពុម្ពអក្សរផ្សេងទៀត ) ឡើយ ព្រោះថាក្នុងយូនីកូដ ព្យញ្ជនៈធម្មតា និង ជើងព្យញ្ជនៈ ត្រូវបានប្រើដោយគ្រាប់ចុចដូចគ្នា ។ ដើម្បីផ្តល់សញ្ញាថា ព្យញ្ជនៈបន្ទាប់ជាជើងព្យញ្ជនៈ គ្រាប់ចុចខាងក្រោមត្រូវបានវាយមុនព្យញ្ជនៈ ៖




ឧទាហរណ៍ ៖

ច + ត + ្ + ត –> ចត្ត

ស + ្ + រ + ី –> ស្រី

ស + ្ + រ + ែ –> ស្រែ

សម្រាប់ព្យាង្គដែលមានជើងពីរ អ្នកត្រូវវាយជើងទាំងពីរតាមលំដាប់នៃការប្រកប ហើយជើងនិមួយៗត្រូវនាំមុខដោយសញ្ញា ្ ៖

ស + ្ + ត + ្ + រ + ី –> ស្ត្រី

សូមប្រាកដថា អ្នកមិនវាយជើង្រ មុនជើងដទៃទៀតឡើយ ត្រូវតែគោរពទៅតាមលំដាប់នៃការប្រកប ។ និង មិនត្រូវវាយជើងព្យញ្ជនៈពីក្រោយស្រៈឡើយ ។

<u>ករណីពិសេសសម្រាប់ព្យញ្ជនៈ</u>

មានករណីមួយចំនួនដែលតួអក្សរខ្លះត្រូវបានបង្ហាញដោយរូបរាងលើសពីមួយ អាស្រ័យតាមអក្សរផ្សេងៗដែលនៅជុំវិញវា ។ ក្នុងករណីអក្សរ ប ពេលតាមពីក្រោយដោយស្រៈ ា ។ ក្នុងពុម្ពអក្សរមុនៗ វាចាំបាច់ត្រូវមានតួអក្សរពិសេសមួយសម្រាប់ករណីនេះ ប៉ុន្តែក្នុងយូនីកូដអ្នកត្រូវវាយគ្រាប់ចុចធម្មតាសម្រាប់ព្យញ្ជនៈ ប ។ នៅពេលដែលអ្នកវាយស្រៈ ា កុំព្យូទ័រ នឹងប្តូររូបរាងអក្សរ ប ភ្លាម ។

ប +ា -> បា

ដូចគ្នានេះដែរ សម្រាប់តួអក្សរ ញ ។ អ្នកមិនចាំបាច់ព្រួយបារម្ភពីរូបរាងនៃព្យញ្ជនៈ ញ ឬ ជើង្ញ ទេ ។ ប្រសិនបើ អ្នកវាយបានត្រឹមត្រូវ នោះកុំព្យូទ័រនឹងបង្ហាញឡើងនូវអក្សរដ៏ត្រឹមត្រូវមួយ ។

ទ +ា + ញ -> ទាញ

ស + ញ + ្ + ញ +ា -> សញ្ញា

ខ + ្ + ញ +ុំ -> ខ្ញុំ

ប + ញ + ្ + ច + េ + ញ -> បញ្ចេញ

កុំវាយ ព +ា ជំនួសឲ្យ ញ ។

<u>ករណីពិសេសសម្រាប់ស្រៈ</u>

មានស្រៈមួយចំនួនដែលទោះបីជាវាមានក្នុងក្តារចុចក៏ដោយ ប៉ុន្តែវាតំណាងឲ្យតួអក្សរពីរផ្សេងគ្នា (ពួកវាគ្មានតួអក្សរផ្ទាល់ក្នុងយូនីកូដទេ) ស្រៈទាំងនេះគឺ ៖

ាំ ុំ ុះ េះ និង ោះ

អ្នកអាចវាយស្រៈទាំងនេះដោយផ្ទាល់ជាមួយគ្រាប់ចុចរបស់ក្តារចុច ប៉ុន្តែប្រសិនបើអ្នកចង់លុបពួកវា អ្នកត្រូវចុច គ្រាប់ចុច <- ពីរដង ។

ផ្ទុយពីនេះ មានស្រៈដែលមានពីរផ្នែកដូចខាងក្រោម (ស្រៈបំបែក) ៖

ើ ឿ ៀ ោ និង ៅ

ពួកវាត្រូវបានវាយដោយគ្រាប់ចុចតែមួយគត់ និងត្រូវបានលុបដោយគ្រាប់ចុច <- តែម្តងដែរ ។
ស្រៈដទៃទៀតដែលមិនមាននៅលើក្តារចុច ទាមទារឲ្យវាយពីរដង ។ ឧទាហរណ៍ ៖

ក + ែ + ះ –> កែះ

<u>តួអក្សរប្តូរព្យញ្ជនៈ</u>

ជួនកាលតួអក្សរមួយត្រូវបានគេហៅថាតួអក្សរប្តូរព្យញ្ជនៈ ដែលត្រូវបានប្រើដើម្បីប្តូរសម្លេងស្រៈ ដែលអមជាមួយព្យញ្ជនៈ ។ តួអក្សរទាំងនេះមានពីរ ៖

ត្រីសព្ទ ( ៊ ) ត្រូវបានប្រើដើម្បីប្តូរសម្លេងស្រៈ ដែលអមព្យញ្ជនៈអឃោសៈ ទៅជាព្យញ្ជនៈឃោសៈ ។ វាត្រូវបានប្រើជាមួយព្យញ្ជនៈអឃោសៈ ដែលមិនសមមូលទៅនឹងព្យញ្ជនៈឃោសៈណាមួយ។ ព្យញ្ជនៈទាំងនេះមាន ៖

ស ហ អ និង ប

មូសិកទន្ត ( ៉ ) ត្រូវបានប្រើដើម្បីប្តូរសម្លេងស្រៈ ដែលអមព្យញ្ជនៈឃោសៈ ទៅជាព្យញ្ជនៈអឃោសៈ ។វាត្រូវបានប្រើជាមួយព្យញ្ជនៈឃោសៈ ដែលមិនសមមូលទៅនឹងព្យញ្ជនៈអឃោសៈណាមួយ។ ព្យញ្ជនៈទាំងនេះមាន ៖

ង ញ ម យ រ និង វ

ករណីលើកលែង ៉ ក៏ត្រូវបានប្រើជាមួយអក្សរ ប ដើម្បីប្តូរសម្លេងរបស់វាពី ប ទៅ ប៉ ។
តួអក្សរប្តូរព្យញ្ជនៈ តែងតែត្រូវបានវាយនៅពីក្រោយព្យញ្ជនៈ និង ជើងព្យញ្ជនៈ ប៉ុន្តែត្រូវវាយនៅពីមុខស្រៈ ។
សមាសធាតុដែលមានតួអក្សរប្តូរព្យញ្ជនៈ មានលំដាប់ដូចខាងក្រោម ៖

ព្យញ្ជនៈ+ ជើងព្យញ្ជនៈ + តួអក្សរប្តូរព្យញ្ជនៈ + ស្រៈ + សញ្ញា

ឧទាហរណ៍ ៖

យ + ៉ +ា + ក –> យ៉ាក

ប + ៉ + េ + ង + ប + ៉ + ោះ –> ប៉េងប៉ោះ

ក +្រ +ុ + ម + ហ + ៊ +ុ + ន –> ក្រុមហ៊ុន

ប + ៊ +ុ + ត –> ប៊ុត

ស + ្ + រ + ៊ +ុ + ប –> ស្រ៊ុប

ម + ្ + ហ + ៊ + ែ + ត –> ម្ហ៊ែត

ពេលដែល តួអក្សរប្តូរព្យញ្ជនៈ ត្រូវបានតាមពីក្រោយដោយស្រៈដែលមានទីតាំងនៅលើព្យញ្ជនៈ ឬដោយស្រៈ ាំ នោះ តួអក្សរប្តូរព្យញ្ជនៈ ប្តូរទីតាំងរបស់ខ្លួនដោយស្វ័យប្រវត្តិមកនៅក្រោមព្យញ្ជនៈសំខាន់ ហើយក៏ប្តូររូបរាងរបស់វាមកជាស្រៈ ុ (ទាំង ៊ និង ៉) ។ អ្នកមិនចាំបាច់វាយស្រៈ ុ ឡើយ ។ ឧទាហរណ៍ខ្លះ ៖

ស + ៊ -> ស៊

ស + ៊ + ី -> ស៊ី

ប + ៉ + ី -> ប៉ី

ប + ន + ្ + ស + ៊ + ី -> បន្ស៊ី

ប្រសិនបើអ្នកវាយស្រៈ ុ ជំនួសឲ្យ ៊ ឬ ៉ នោះអ្នកប្រាកដជាមិនអាចវាយស្រៈពីរបន្តគ្នាបានឡើយ ៖

ស + ុ + ី -> សុី

មានករណីលើកលែងចំនួនបីចំពោះ តួអក្សរប្តូរព្យញ្ជនៈ ដែលមិនបានប្តូរទីតាំងមកក្រោម ទោះជាមានស្រៈនៅពីលើព្យញ្ជនៈនោះក៏ដោយ ។ កុំព្យូទ័រនឹងរៀបចំលំដាប់ដ៏ត្រឹមត្រូវ សម្រាប់អក្សរដែលអ្នកបានវាយ ។

វានឹងមិនប្តូររូបរាងពេលដែលស្រៈខាងលើជាស្រៈ ំ ពីព្រោះបន្សំរវាងស្រៈ ំ និង រូបរាងដែលប្តូរមកក្រោមរបស់ តួអក្សរប្តូរព្យញ្ជនៈ អាចឲ្យអាចច្រឡំនឹងស្រៈ ុំ ។ ដូចគ្នានេះដែរ សម្រាប់ស្រៈទាំងអស់ដែលត្រូវបានដាក់នៅលើព្យញ្ជនៈ ។ ប្រសិនបើមិនបានផ្សំជាមួយតួអក្សរប្តូរព្យញ្ជនៈទេ នោះតួអក្សរប្តូរព្យញ្ជនៈ នឹងស្ថិតនៅលើព្យញ្ជនៈដដែល ។

អ + ៊ + ំ -> អ៊ំ

វានឹងមិនប្តូររូបរាងពេលដែលព្យញ្ជនៈ ប ត្រូវបានប្រើផ្សំជាមួយ ៊ ពីព្រោះ អ្នកអាននឹងមិនដឹងថាតើទម្រង់ខាងក្រោមតំណាងឲ្យ ៊ ឬ ៉ ( ដូច្នេះ ប្រសិនបើវាបញ្ចេញសម្លេងជាស្រៈ នោះវាត្រូវផ្លាស់ប្តូរ ឬ បើវាបញ្ចេញសម្លេងជាព្យញ្ជនៈ គួរតែប្តូរ ប៉ ជំនួសឲ្យ ប ) ។

ប + ៊ + ិ + ក -> ប៊ិក

ពេលមានព្យញ្ជនៈមួយ និង ជើងព្យញ្ជនៈមួយ ហើយមួយក្នុងចំណោមពួកវាជា ហ ។ ការវាយត្រូវគោរពតាមវចនានុក្រម ជួនណាតជានិច្ច ។ នេះប្រហែលដោយសារតែ ព្យញ្ជនៈផ្សេងទៀតក្នុងព្យាង្គអាចជាព្យញ្ជនៈឃោសៈ ។ ប្រសិនបើ តួអក្សរប្តូរព្យញ្ជនៈ ត្រូវបានប្តូរចុះក្រោម វាមិនច្បាស់ថាតើ ៊ អនុវត្តទៅលើ ហ ឬ ៉ អនុវត្តទៅលើព្យញ្ជនៈផ្សេងទៀត ។

អ + ្ + ហ + ៊ + ិ + ះ -> អ្ហ៊ិះ

<u>សញ្ញា</u>

មានសញ្ញាបីប្រភេទ ក្នុងភាសាខ្មែរដែលបង្កើតជាផ្នែកនៃព្យាង្គ៖

របាទ ( ៌ ) ៖ របាទ គឺជាសញ្ញាមួយដែលខ្ចីមកពីភាសាឥណ្ឌា ហើយដែលមានសម្លេងស្មើនឹងការដាក់អក្សរ រ នៅពីមុខព្យញ្ជនៈដែលវាស្ថិតនៅពីលើ ។ វាត្រូវបានចាត់ទុកខុសពីសញ្ញាដទៃទៀត ។ ៌ តែងតែត្រូវបានវាយបន្ទាប់ពីព្យញ្ជនៈដែលវាស្ថិតនៅពីលើ និងមុខស្រៈដែលត្រូវវាយ ។ ព្យាង្គដែលមានរបាទ ( ៌ ) មិនអាចមានតួអក្សរជើង ឬ សញ្ញា ស្រៈ ដែលត្រូវដាក់នៅពីលើព្យញ្ជនៈពិសេសឡើយ ។ ពេលប្រើរបាទ ព្យាង្គត្រូវមានទម្រង់បែបនេះ ៖

ព្យញ្ជនៈ + របាទ {+ ស្រៈ} {+សញ្ញា}

ដូចជា ៖

ព + ណ + ៌ -> ពណ៌

ស + គ + ៌ + ៈ -> សគ៌ៈ

ក + ប + ៌ + ូ + រ -> កប៌ូរ

ក + ា + ប + ៌ + ា + ស -> កាប៌ាស

ស + ព + ៌ + េ + ជ + ្ + ញ -> សព៌េជ្ញ

សញ្ញាដទៃទៀតដែលត្រូវដាក់ពីលើព្យញ្ជនៈសំខាន់ ( ៉ ៊ ់ ៍ ៎ ៏ ). ទណ្ឌឃាត ( ៍ ), សំយោគសញ្ញា ( ៎ ) អស្តា ( ៏ ) កាកបាទ ( ៉ ) វិរាម ( ៑ ) និង បន្តក់ ( ់ ) ត្រូវបានដាក់នៅពីលើព្យញ្ជនៈសំខាន់ ។ ជាធម្មតា គេមិនប្រើពួកវាផ្សំជាមួយស្រៈទេ ប៉ុន្តែក្នុងករណីដែលប្រើជាមួយស្រៈ ពួកវាគួរតែត្រូវបានវាយបន្ទាប់ពី ស្រៈ និង មុនសញ្ញាមួយដែលនៅពីក្រោយព្យាង្គ។ ពេលប្រើជាមួយស្រៈ ុ (សូមកុំច្រឡំជាមួយតួអក្សរប្តូរព្យញ្ជនៈ ៊ ឬ ៉ )។ យើងមានរូបមន្តដូចខាងក្រោម ៖

ព្យញ្ជនៈ + ជើង + តួអក្សរប្តូរព្យញ្ជនៈ + ស្រៈ + សញ្ញាលើ + សញ្ញាក្រោយ

ល + ក + ់ -> លក់

ទ + ំ + ព + ័ + រ -> ទំព័រ

ណ + ុ + ះ -> ណុះ

ន + ុ + ំ + ះ -> នុំះ

មានករណីលើកលែងពីរដែលត្រូវបានប្រតិបត្តិដោយកុំព្យូទ័រដោយស្វ័យប្រវត្តិ ប៉ុន្តែអ្នកគួរតែកត់ចំណាំពួកវាផងដែរ ៖
ជួនកាលស្រៈលើអាចផ្សំជាមួយកាកបាទ ដូចជា ៖

អ + ី + ំ + ះ -> អីំះ

- បន្សំរវាង ិ + ៍ ត្រូវបានប្រើចំពោះពាក្យជាច្រើន ។ ពុម្ពអក្សរពីមុខៗខ្លះ មានតួអក្សរពិសេសបែបនេះ ។ ក្នុងយូនីកូដ តួអក្សរទាំងពីរត្រូវវាយដោយឡែកពីគ្នា ប៉ុន្តែវាអាចផ្សំចូលគ្នាបានយ៉ាងត្រឹមត្រូវ ដូចក្នុងឧទាហរណ៍ខាងក្រោម ៖

ព + ោ + ធ + ិ + ៍ -> ពោធិ៍

ចំណាំផ្នែកបច្ចេកទេស ៖ នេះគ្រាន់តែជាការចំណាំផ្នែកបច្ចេកទេសប៉ុណ្ណោះ ។ ដើម្បីងាយស្រួលក្នុងការអាន យើងបានហៅ ំ ថាជាស្រៈ ក៏ប៉ុន្តែយូនីកូដ បានចាត់ទុក ំ ថាជាសញ្ញាមួយមិនមែនជាស្រៈទេ ។ តួអក្សរ ាំ និង ុំ ត្រូវបានបង្កើតឡើង ដោយបន្សំរវាងស្រៈ ា និង ុ ជាមួយនឹងសញ្ញា ំ (សញ្ញា និគ្គហិត). ស្រៈទាំងពីររបស់ខ្មែរ (ាំ និង ុំ) មាននៅលើក្តារចុច ដើម្បីសម្របទៅតាមវប្បធម៌របស់ខ្មែរ ប៉ុន្តែ ក្តារចុចបានបង្កើតតួអក្សរ ា ឬ ុ និង បន្ទាប់មកតួអក្សរ ំ ។ ដូចគ្នាផងដែរចំពោះស្រៈ ុះ, េះ និង ោះ. ពួកវាត្រូវបានបង្កើតដោយស្វ័យប្រវត្តិដោយក្តារចុច ប៉ុន្តែអ្នកត្រូវតែយល់ថា ពេលដែលយើងចុចស្រៈមួយក្នុងចំណោមស្រៈទាំងនេះ ក្តារចុចត្រូវបង្កើតស្រៈ (ុ េ ឬ ោ ) មុន បន្ទាប់មកទើបសញ្ញា រះមុខ (ះ) ។

សញ្ញាដាក់ពីក្រោយព្យញ្ជនៈ ដែលជាផ្នែកមួយនៃព្យាង្គ និង មានឥទ្ធិពលដល់ការបញ្ចេញសម្លេង (ះ និង ៈ). រះមុខ ( ះ ) និង យុគលពិន្ទុ ( ៈ ) តែងតែត្រូវបានដាក់នៅពីក្រោយបង្អស់នៃព្យាង្គ ។ ពួកមិនអាចត្រូវបានច្រឡំនឹងសញ្ញាវណ្ណយុត្តិចំណុចពីរគូ ( ៖ ).

ក + ែ + ះ -> កែះ

សញ្ញាវណ្ណយុត្តិ ( ។ ៕ ៖ ៗ ៚ ៙ ! . " ? )

អក្សរខ្មែរមានសញ្ញាវណ្ណយុត្តិ ដូចជា ៖ សញ្ញា ខណ្ឌ ( ។ ) សញ្ញា បរិយោសាន ( ៕ ) សញ្ញា Camnuc pii Kuuh ( ៖ ), សញ្ញា លេខទោ ( ៗ ) សញ្ញា ភ្នែកមាន់ ( ៙ ) និង សញ្ញា គោមូត្រ ( ៚ ).

បន្ថែមពីលើនេះផងដែរ សញ្ញាវណ្ណយុត្តិខ្លះ ត្រូវបានខ្ចីពីអក្សរឡាតាំង ដូចជា សញ្ញា ឧទាន( ! ) សញ្ញា ចុច( . ) សញ្ញា វិឡារ( " ) និង សញ្ញា សួរ ( ? ) ។ សញ្ញាចុចត្រូវបានប្រើសម្រាប់តែទម្រង់កាត់ ។ សញ្ញាវណ្ណយុត្តិក្នុងភាសាខ្មែរ ជាទូទៅត្រូវបានបំបែកចេញពីពាក្យដែលនៅខាងមុខ និង ខាងក្រោយ ដោយដកឃ្លាមួយ លើកលែងតែប្រើជាមួយសញ្ញាលេខទោ (ៗ) ។ ចំណែកឯ សញ្ញាវណ្ណយុត្តិរបស់ឡាតាំងជាទូទៅមិនត្រូវបានដកឃ្លាចេញពីពាក្យដែលនៅពីខាងមុខវាទេ លើកលែងតែប្រើជាមួយសញ្ញាវិឡារ (ពាក្យដែលនៅពីក្រោយ វិឡារបើក និង ពាក្យដែលនៅមុខវិឡាបិទមិនត្រូវបានដកឃ្លា)

ក្នុងភាសាខ្មែរ the space (ដកឃ្លា) ក៏ត្រូវបានចាត់ទុកថាជាសញ្ញាវណ្ណយុត្តិ ដែលប្រើដើម្បីផ្អាកសម្ដីក្នុងការនិយាយ មិនមែនដើម្បីបំបែកពាក្យទេ ។ ដើម្បីវាយដកឃ្លា អ្នកត្រូវចុចគ្រាប់ ប្ដូរ (SHIFT) និង ចុច ចន្លោះមិនឃើញ(Spacebar) ក្នុងពេលដំណាលគ្នា ។

អំពីបន្សំ

ក្នុងពុម្ពអក្សរយូនីកូដ ពេលដែលព្យញ្ជនៈមួយត្រូវបានតាមពីក្រោយដោយស្រៈ ា នោះវានឹងប្ដូររូបរាងបន្តិច ដើម្បីឲ្យបានស្អាតជាងមុន ។ ប្រសិនបើ ា ត្រូវបានលុបទៅវិញ នោះព្យញ្ជនៈនឹងប្ដូរទៅកាន់ទ្រង់ទ្រាយដើម ។ ជាធម្មតា អ្នកប្រើមិនដឹងពីរបៀបបន្សំនេះទេ ពួកគេគ្រាន់តែចង់បានអត្ថបទដែលមានភាពល្អស្អាត ។ សូមយកចិត្តទុកដាក់លើចំណុចនេះ ៖

# ត ា តា

អ្នកអាចឃើញពីការប្រែប្រួលរបស់សក់ ត ពេលដែលផ្សំជាមួយស្រៈ ា ។

បន្សំមួយទៀតក្នុងអក្សរខ្មែរ ដែលមានការផ្លាស់ប្ដូររូបរាងដែរនោះ គឺរវាងអក្សរ វ មូល និង ិ ។

**ទន្ទ** ត្រូវបានប្រើជំនួសឲ្យ **ទិន្ទ**

ចន្លោះមិនឃើញ (ZWSP)

ពាក្យក្នុងភាសាខ្មែរត្រូវបានវាយបន្តបន្ទាប់គ្នា និងខណ្ឌចែកគ្នាដោយសញ្ញាវណ្ណយុត្តិណាមួយ ។ កម្មវិធីវាយបញ្ចូលអត្ថបទ កម្មវិធីរុករកអ៊ីនធឺណិត និងកម្មវិធីដទៃទៀតដែលមានទ្រង់ទ្រាយជាអត្ថបទ ចាំបាច់ត្រូវដឹងពីកន្លែងដែលត្រូវបំបែកប្រយោគនិមួយៗដើម្បីចុះបន្ទាត់ថ្មី ។ ក្នុងភាសាលោកខាងលិច ដែលប្រើចន្លោះដើម្បីបំបែកពាក្យនោះ ប្រាកដជាមិនមានបញ្ហាឡើយ ប៉ុន្តែក្នុងភាសាខ្មែរ កម្មវិធីទាំងនេះមិនបានដឹងពីកន្លែងដែលត្រូវបញ្ចប់ពាក្យ និង ត្រូវចុះបន្ទាត់ថ្មីឡើយ។

ក្នុងកាសែតភាគច្រើននៅកម្ពុជា ការចុះបន្ទាត់ត្រូវធ្វើឡើងដោយដៃ ។ អ្នកសរសេរអត្ថបទត្រូវគណនាថាតើពាក្យបន្ទាប់នោះអាចដាក់ក្នុងបន្ទាត់ជាមួយគ្នាបានឬអត់ បន្ទាប់មកពួកគេនឹងធ្វើការលើបន្ទាត់នោះដោយដៃ ។

ក្នុងទំព័របណ្តាញមិនអាចប្រើមធ្យោបាយនេះបានទេ ព្រោះទ្រង់ទ្រាយទំព័រត្រូវបានពឹងផ្អែកទៅលើទំហំនៃបង្អួចរបស់កម្មវិធីរុករកលើកុំព្យូទ័រអ្នកប្រើ និង ទៅលើគុណភាពបង្ហាញរបស់អេក្រង់។

ដំណោះស្រាយសម្រាប់បញ្ហានេះ គឺត្រូវបញ្ចូលចន្លោះមើលមិនឃើញរវាងពាក្យទាំងនោះ ដែលចន្លោះនោះជាចន្លោះប្រើគ្រាន់តែសម្រាប់ខណ្ឌចែកពីពាក្យមួយទៅពាក្យមួយទៀត និងដើម្បីឲ្យកម្មវិធីទាំងនោះដឹងពីកន្លែងដែលត្រូវចុះបន្ទាត់ប៉ុណ្ណោះ ដូចនេះយើងមិនអាចមើលឃើញគម្លាតរវាងពាក្យនោះទេ ។

តួអក្សរនេះត្រូវបានហៅថា ចន្លោះមិនឃើញ ហើយវាគឺជាតួអក្សរដែលប្រើញឹកញាប់បំផុតក្នុងអត្ថបទ ( ក្នុងការចុចគ្រាប់ចុច១០០ មាន ចន្លោះមិនឃើញ ១៦ ចន្លោះ ) ដូច្នេះទើបយើងសម្រេចដាក់គ្រាប់ចុចដែលប្រើជាងគេនេះលើគ្រាប់ចុចដែលងាយចុចបំផុតនោះ គឺ ចន្លោះមិនឃើញ (Spacebar) ។ គ្រប់ពេលដែលអ្នកចុចចន្លោះមិនឃើញ នោះអ្នកនឹងបញ្ចូលចន្លោះបំបែកមួយ ។

ប្រសិនបើអ្នកចុចចន្លោះមិនឃើញ spacebar ( ដោយមិនបានចុចគ្រាប់ចុចផ្សេងទៀត ) នោះតួអក្សរដែលបានបញ្ចូលទៅក្នុងអត្ថបទ គឺជាចន្លោះមួយដែលមើលមិនឃើញ ។

ប្រសិនបើអ្នកចង់វាយ ដកឃ្លា អ្នក ត្រូវចុច គ្រាប់ចុច ប្តូរ (SHIFT) ផ្សំជាមួយគ្រប់ចុច ចន្លោះមិនឃើញ (spacebar) ។

ចន្លោះភ្ជាប់ (Nonbreakable Space)

ជាទូទៅ មិនថានៅក្នុងភាសាណាជាភាសាណានោះទេ ចាំបាច់ត្រូវតែមានព្យាង្គ ពាក្យ ឃ្លា ប្រយោគ ។ ការរួមផ្សំនៃសមាសភាគទាំងនេះបានត្រឹមត្រូវ នឹងបង្កើតបានជាកថាខណ្ឌនៃអត្ថបទមួយដ៏មានអត្ថន័យ និង ខ្លឹមសារ ។ កត្តាសំខាន់គឺយើងត្រូវដឹងថា តើ ព្យាង្គ ពាក្យ ឃ្លា និង ប្រយោគមានលក្ខណៈខុសគ្នាត្រង់ណា? ហើយគេសម្គាល់វាបានដោយសារអ្វី ? យើងសង្ឃឹមថា អ្នកពិតជាបានដឹងហើយតាមរយៈការសិក្សាវេយ្យាករណ៍ខ្មែរ ។ ត្រង់ចំណុចនេះ យើងសូមសង្កត់ធ្ងន់ ទៅលើតែប្រយោគតែប៉ុណ្ណោះ ។

ប្រយោគគឺជាបន្សំពាក្យដែលមានន័យគ្រប់គ្រាន់ ហើយអាចស្តាប់បាន និង បញ្ចប់ដោយសញ្ញាវណ្ណយុត្តិណាមួយដូចជា ( ។ ? ! .....) ដោយខានមិនបាន ។ ដូចគ្នានេះដែរ ចំពោះភាសាលោកខាងលិច ក៏មានការបញ្ចប់ដោយសញ្ញាណាមួយដែរ តែខុសគ្នាត្រង់ថា រវាងពាក្យ និង សញ្ញាទាំងនោះគឺពុំមានគម្លាតឡើង ដូចនេះ បង្កលក្ខណៈងាយស្រួលដល់អ្នកវាយអត្ថបទ ដោយពុំមានការធ្លាក់តែសញ្ញាមួយណានោះតែឯងមកបន្ទាត់ថ្មីឡើយ ។

ដោយឡែក ចំពោះភាសាខ្មែរ ដោយគោរពតាមក្បួនវេយ្យាករណ៍ ក្នុងការសរសេរ រវាងប្រយោគមួយទៅប្រយោគមួយ ត្រូវតែខណ្ឌគ្នាដោយសញ្ញាវណ្ណយុត្តិណាមួយ ហើយពាក្យដែលនៅអមសញ្ញានោះត្រូវធ្វើការដកឃ្លា ។ ការនេះ ធ្វើឲ្យមានលក្ខណៈពិបាកខ្លះដល់អ្នកវាយអត្ថបទ ព្រោះនៅពេលដែលសញ្ញាវណ្ណយុត្តិនោះ ស្ថិតនៅខាងចុងកថាខណ្ឌ បើកាលណាអ្នកដកឃ្លា នោះបណ្តាលឲ្យសញ្ញានៅធ្លាក់មកនៅលើបន្ទាត់ថ្មីតែឯង ជាហេតុនាំឲ្យអត្ថបទរបស់យើងបាត់បង់នូវសោភណភាព ។

ដើម្បីជៀសវាងនូវបញ្ហានេះ ក្នុងប្រព័ន្ធកុំព្យូទ័រ យើងបានបង្កើតនូវ គ្រាប់ចុចពិសេស ដែលមានឈ្មោះថា ចន្លោះភ្ជាប់ ។ ចន្លោះភ្ជាប់ គឺជាបន្សំនៃគ្រាប់ចុច ឆ្លាស់(Alt (Gr)) និង គ្រាប់ចុចចន្លោះមិនឃើញ (Space) ។

រូបមន្ត ពាក្យ + គ្រាប់ចុចឆ្លាស់ + គ្រាប់ចុចចន្លោះមិនឃើញ + សញ្ញាវណ្ណយុត្តិ

(គ្រាប់ចុចឆ្លាស់ + គ្រាប់ចុចចន្លោះមិនឃើញ = ចន្លោះភ្ជាប់)

ការបន្ថែមចន្លោះភ្ជាប់រវាងពាក្យ និង សញ្ញាវណ្ណយុត្តិនេះ មានន័យថា អ្នកនឹងតែអាចមើលឃើញចន្លោះរវាងពាក្យ និង សញ្ញានោះជាធម្មតា តែបង្កប់នូវលក្ខណៈពិសេស ដោយវាជួយភ្ជាប់ពាក្យនិង សញ្ញានោះឲ្យនៅជាប់គ្នា ប្រសិនបើធ្លាក់ គឺត្រូវធ្លាក់ទាំងពាក្យដែលនៅជាប់វាមកជងដែរ មិនអាចសញ្ញាតែឯងនោះទេ ។

ចន្លោះភ្ជាប់នេះ ក៏អាចប្រើជាមួយតួអក្សរផ្សេង ក្រៅពីសញ្ញាវណ្ណយុត្តិដែរ ហើយវានៅរក្សាលក្ខណៈដើម គឺដកឃ្លាតែមិនចុះបន្ទាត់នៅចុងបន្ទាត់ ។

អនុវត្តន៍

បន្ទាប់ពីបានសិក្សារួចមក យើងសង្ឃឹមថា ឥឡូវនេះអ្នកនឹងអាចយល់ពីយន្តការនៃការវាយអក្សរខ្មែរ ដោយប្រើពុម្ពអក្សរយូនីកូដ ។ ដូចនេះ ចូរអនុវត្តវាយអត្ថបទដូចខាងក្រោម ៖

# ការវាយកម្រិតខ្ពស់

មានតួអក្សរមួយចំនួនក្នុងភាសាខ្មែរដែលកម្រត្រូវបានប្រើ ។ តួអក្សរទាំងនេះ ប្រើសម្រាប់ភាសាខ្មែរ បុរាណ និង ភាសាបាលី និង សំស្ក្រឹត ដូច្នេះពួកវាមិនត្រូវបានបោះពុម្ពលើក្ដារចុចឡើយ ប៉ុន្តែយើងអាចប្រើវាបានដោយចុចគ្រាប់ចុចដូចខាងក្រោម ៖

Old Khmer, Sanskrit and Pali

Alt Gr + B -> ឞ

Alt Gr + K -> ឝ

Alt Gr + T-> ឨ

Alt Gr + Q -> ៜ

Alt Gr + W -> ៝

Divination signs

Shift + Alt Gr + 1 -> ៱

Shift + Alt Gr + 2 -> ៲

Shift + Alt Gr + 3 -> ៳

Shift + Alt Gr + 4 -> ៴

Shift + Alt Gr + 5 -> ៵

Shift + Alt Gr + 6 -> ៶

Shift + Alt Gr + 7 -> ៷

Shift + Alt Gr + 8 -> ៸

Shift + Alt Gr + 9 -> ៹

Shift + Alt Gr + 0 -> ៰

Lunar dates:

Shift + Alt Gr + Q -> ᧠

Shift + Alt Gr + W -> ᧡

Shift + Alt Gr + E -> ᧢

Shift + Alt Gr + R -> ᧣

Shift + Alt Gr + T -> ᧤

Shift + Alt Gr + Y -> ᧥

Shift + Alt Gr + U -> ᧦

Shift + Alt Gr + . -> ᧿

Shift + Alt Gr + I -> ᧧

Shift + Alt Gr + O -> ᧨

Shift + Alt Gr + P -> ᧩

Shift + Alt Gr + [ -> ᧪

Shift + Alt Gr + ] -> ᧫

Shift + Alt Gr + A -> ᧬

Shift + Alt Gr + S -> ᧭

Shift + Alt Gr + D -> ᧮

Shift + Alt Gr + F -> ᧯

Shift + Alt Gr + G -> ᧰

Shift + Alt Gr + H -> ᧱

Shift + Alt Gr + J -> ᧲

Shift + Alt Gr + K -> ᧳

Shift + Alt Gr + L -> ᧴

Shift + Alt Gr + ; -> ᧵

Shift + Alt Gr + ` -> ᧶

Shift + Alt Gr + Z -> ᧷

Shift + Alt Gr + X -> ᧸

Shift + Alt Gr + C -> ᧹

Shift + Alt Gr + V -> ᧺

Shift + Alt Gr + B -> ᧻

Shift + Alt Gr + N -> ᧼

Shift + Alt Gr + M -> ᧽

Shift + Alt Gr + , -> ᧾